AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com

អ្នកព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ

# ច្បាប់ក្រមង៉ុយ

~ ច្បាប់ល្បើកថ្មី

~ ច្បាប់កេរកាលថ្មី

~ សេចក្ដីរំលឹកដាស់តឿន

~ ពាក្យកាព្យប្រដៅជនប្រុសស្រី



ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥១៦

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com

# ច្បាប់ក្រមង៉ុយ

- ច្បាប់លើកថ្មី
- ច្បាប់កេរកាលថ្មី
- សេចក្ដីរំលឹកដាស់តឿន
- ពាក្យកាព្យប្រដៅជនប្រុសស្រី

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



## អារម្ភកថា

ច្បាប់ក្រមង៉ុយនេះកាលបោះពុម្ពលើកមុនៗ ចែកចេញជាបីសៀវភៅ គឺសៀវភៅទី១ មានច្បាប់ល្បើកថ្មី និងកេរកាលថ្មី. ទី២ សេចក្តីដាស់តឿន និងទី៣ពាក្យកាព្យប្រដៅជនប្រុសស្រី ។ នៅគ្រាបោះពុម្ពលើកទី៦នេះ ដោយនិយមតាមសេចក្តីស្នើពីមជ្ឈដ្ឋានអ្នកសិក្សាជាច្រើននាក់ដែលសុំអោយយើងផ្តុំគ្នាយកច្បាប់នេះមករួមគ្នាជាសៀវភៅមួយ ត្បិតទុកអោយនៅដោយឡែកៗជាកូនសៀវភៅតូចៗនោះនាំអោយរប៉ាត់រប៉ាយ ពិបាកថែរទាំ ។ យោបល់នេះត្រឹមត្រូវណាស់ ទើបយើងសម្រេចប្រមូលផ្តុំបានជាសៀវភៅមួយនេះឡើង ។

ចំពោះពាក្យពេចន៍ កាព្យឃ្លោងទាំងអស់នៅក្នុងច្បាប់ទាំងប៉ុន្មាននេះ យើងគ្មានប៉ះពាល់កែប្រែសោះឡើយ សម្រួលតែរបៀបតម្រៀបឃ្លាល្បះអោយមានលំនាំទៅតាមបែបកាព្យត្រឹមត្រូវប៉ុណ្ណោះ ។

គោលបំណងធំរបស់យើងខ្ញុំមួយទៀត គឺការចង់រក្សាស្នាដៃដ៏មានតម្លៃនៃលោកតាកវី **ភិរម្យង៉ុយ ឬក្រមង៉ុយ** ព្រោះពាក្យសំដីរបស់លោកក្នុងនេះទាំងអស់សុទ្ធតែមានន័យទូលំទូលាយ ហើយប្រកបដោយខ្លឹមសារល្អណាស់មិនចេះហួសសម័យកាលនោះផង តាំងពីគ្រាលោកសរសេររហូតសព្វថ្ងៃនៅតែមានន័យត្រូវគួរនិងធ្វើគតិទូន្មានខ្លួនបាន ។

ឆ្លៀតឱកាសនេះ ពុទ្ធសាសនបណ្ឌិតសុំសម្តែងគារវកិច្ចដ៏ជ្រាលជ្រៅចំពោះវិញ្ញាណក្ខន្ធនៃលោកកវីដ៏ឆ្នើមនេះផង ។

ភ្នំពេញ ខែ សីហា ឆ្នាំ ១៩៧២

**ពុទ្ធសាសនបណ្ឌិត្យ**

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com

# បណ្តាំក្រមង៉ុយ

## LES RECOMMANDATIONS DE KRAM NGOY

១- នេះបទព្រហ្មប្រាជ្ញប្រែ ប្រាយប្រាប់ខ្មែរទាំងប្រុសស្រី
ឱយប្រិតប្រុងស្មារតី គួរគប្បីឱយឧស្សាហ៍ ។
កុំខ្ជិលកុំល្ងង់ពេក ខំរៀនលេខរៀនអក្ខរា
រៀនគ្រប់សព្វធម៌អាថ៌ ប្រាជ្ញាផ្សំនឹងគំនិត ។
កំណើតកើតជាមនុស្ស មើលឱយធ្លុះទោះឆ្ងាយជិត
ចេះស្ទាត់ប្រាកដពិត គិតការអ្វីបានគ្រប់យ៉ាង ។
មនុស្សល្ងង់មិនផ្អើលភ្ញាក់ ដូចភ្នែកខ្វាក់ទាំងសងខាង
មានរូបគ្មានអ្វីអាង សាងទាបថោកកើតមកខ្លៅ ។
៥- ពូជមនុស្សទោះខ្ពស់ទាប កាត់តាមភាពត្រកូលផៅ
អាក្រក់ល្អសខ្មៅ កាត់កូនចៅដូចដូនតា ។
ពូជល្ងង់មិនបានបួស ទុកជាទោសនឹងសាសនា
អ្នកបួសចេះធម៌អាថ៌ កូនសិក្សាខំរៀនសូត្រ ។
ពូជខ្លៅមិនសូវប្រាជ្ញ ពូជកោងកាចមិនសូវស្លូត
ពូជត្រង់ៗរហូត ពូជភរភូតមិនផុតផៅ ។
ឪពុកម្តាយស្លូតត្រង់ ចិត្តមិនចង់ឱយកូនខ្លៅ
ជេរវាយស្តីប្រដៅ ឱយកូនចៅបានចេះដឹង ។
ឪពុកគ្មានតិរិះ ឃើញកូនចេះមិនដែលខឹង

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



យើញកូនខំប្រិតប្រឹង　　ឪពុកដឹងតែងត្រេកអរ ។
១០- ដាស់តឿនក្រើនរំលឹក　　ដេរល្ងាចព្រឹកខ្លាចកូនក្រ
ចង់ឱយតែកូនល្អ　　លោមអង្វរឱយកូនខំ ។
កូនកាចបំពេញទុក្ខ　　ម្ដាយឪពុកមានបារម្ភ
កូនស្លូតដឹងគួរសម　　មេបាថ្កុំថ្កើងកេរ្ដិ៍ឈ្មោះ ។
ឪពុកម្ដាយខ្សត់ខ្សោយ　　កុំបណ្ដោយឱយអាប់យស
ខំរៀនឱយបានខ្ពស់　　គ្រាន់សង្គ្រោះដល់មេបា ។
អ្នកល្ងង់ហេតុពីខ្ជិល　　ឥតមន្ទិលរឿងធមិអាថិ
គួរកូនចៅសិក្សា　　រៀនអក្ខរាទាំងប្រុសស្រី ។
កាលអង្គព្រះសាស្ដា　　មានថេរាមានថេរី
ភិក្ខុភិក្ខុនី　　ធមិបាលីចេះចាំស្ទាត់ ។
១៥- លោកសង្ឃខ្លះចេះស្ទើរ　　ចេះភ្លើៗធ្វើឱយភ្លាត់
ព្រះអង្គទ្រង់សន្មត　　សិក្ខាបទដល់ឥឡូវ ។
ទំលាប់ទំនៀមខ្មែរ　　ខំធ្វើស្រែចង់បានស្រូវ
អ្នករៀនច្បាប់ខុសត្រូវ　　ទុកជាផ្លូវភ្លឺប្រាជ្ញា ។
ស្រុកសៀមលាវបារាំង　　ចេះតាំងពីដូនតា
ចេះលេខចេះអក្ខរា　　សរសេរចារទាំងប្រុសស្រី
ជាតិខ្មែរមិនចេះខ្មាស　　នាំពីចាស់គំនិតខ្លី
ល្ងង់ដប់ចេះពីរបី　　ចេះជួញក្ដីមិនចេះច្បាប់ ។
មិនចេះលេខអក្សរ　　មុខមាត់ល្អប្រាជ្ញារអាប់
ឈ្មោះខ្លួនភ្នែកខ្លួនស្រាប់　　គេសូត្រប្រាប់ទើបបានដឹង ។

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



២០- ភ្នែកជាភ្លីក្រឡៃត    ល្ងង់ព្រោះហេតុមិនខំប្រឹង
កើតទាស់មានចិត្តខឹង    ពឹងរកគេសរសេរឱយ ។
មនុស្សក្រហេតុពីខ្ជិល    មិនរមិលមើលមុខក្រោយ
ម្យ៉ាងខ្សត់ពីព្រោះខ្ជះខ្ជាយ    ញីកខាងឱយរង្វើលរក ។
ម្យ៉ាងក្រពីព្រោះល្ងង់    ជួញលិចលង់មិនលៃលក
ទិញថ្លៃទៅលក់ថោក    ចេះតែយកមិនគិតយល់ ។
អ្នកមាន១គំនិត    ដេកដើរគិតកើតរវល់
ប្រាជ្ញាជាឫសគល់    កើតអំពល់អំពីទ្រព្យ ។
អ្នកល្ងង់នឹងអ្នកចេះ    បើនឹងរិះរាយរៀបរាប់
អ្នកចេះប្រសើរគាប់    ល្ងង់ឥតភ័ព្វអាប់រាសី ។
២៥- មានរូបមានជីវិត    មិនចេះគិតចង់ដឹងអ្វី
រូបប្រុសឫកដូចស្រី    នឹងហ៊ានស្តីគ្មានគេស្តាប់ ។
ល្ងង់ម្យ៉ាងមានអំណាច    ល្ងង់កោងកាចអួតចាក់កាប់
ឆាប់ខឹងមិនដឹងច្បាប់    កាលណាស្លាប់គេត្រេកអរ ។
អ្នកចេះតិះដល់    អ្នកល្ងង់ឆ្ងល់មិនសល់ក្រ
ចេះល្អិតចិត្តជាល្អ    សួយអាករចូលមិនខ្វះ ។
ចេះម្យ៉ាងមានអំណាច    អ្នកខ្លៅខ្លាចឱនសំពះ
គេខុសជេរជៀលត្មះ    អ្នកខ្លៅខ្លះគេលបខឹង ។
ប្រាជ្ញម្យ៉ាងចេះសព្វសុស    ប្រព្រឹត្តខុសនោះមិនដឹង
មិនគិតពិនិត្យថ្លឹង    ប្រាជ្ញប្រិតប្រឹងប្រដៅគេ ។
៣០- កូនចៅទោះធំតូច    ខុសខិលខូចខឹងវាយជេរ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



មារយាទខ្លួនខុសគេ មិនគ្នាន់ក្មេរកិរិយាឯង ។
កូនចៅទាំងស្រីប្រុស ការត្រូវខុសគួរគិតក្រែង
គិតគ្រប់សព្វកន្លែង តែងនឹងមានរាល់រូបកាយ ។
ភ្នែកបើកភ្លឺមែនពិត មើលឃើញជិតៗវៀងអាយ
ភ្នែកធ្មេចមើលឃើញឆ្ងាយ សព្វសុសសាយមិនសេសសល់ ។
រៀនរកស៊ីលក់ទិញ ខាតចំណេញគិតឱយដល់
ឱយដឹងការកិច្ចកល ទើបកើតផលប្រយោជន៍ខ្លួន ។
ឱយរៀនលេខនព្វន្ត បូកហាគុណឱយមាំមួន
ដីសនិងក្ដារធ្នួន ក្រែងមិនយួនចំបាត់បាន ។
៣៩- ជញ្ជីងភ្នែកមានល្បាក់ មើលឱយជាក់កុំប្រមាណ
ក្រែងខុសខាតមិនខាន ធ្លាប់រាប់អានកុំទុកចិត្ត ។
ភ្នែកមនុស្សធំរលីង ភ្នែកជញ្ជីញគេចុចល្អិត
អ្នកល្ងង់ថ្លឹងប្រឹងប្រិត ព្រោះអាណិតខ្មែរល្ងង់ខ្លៅ ។
មិនមានពីដូរលក់ ស្រូវកន្ទក់កន្ដាំងតៅ
របស់ទោះឆ្អិនឆៅ សំពត់អាវខោខ្មៅស ។
ខ្មែរអាងស្រូវក្នុងជោក ដូរថ្លៃថោកអាក្រក់ល្អ
អស់ស្រូវទៅជាក្រ អង្វរចិនជឿស្រូវឯង ។
ធ្វើស្រែនឿយហត់ណាស់ មិននៅផ្ទះដេកចំខែង
ផ្ទះចិនពីរបីល្វែង មានកន្លែងជង្រុកស្រូវ ។
៤០- ជាតិខ្មែរឥតគំនិត ស៊ីមិនគិតមើលខុសត្រូវ
ជឿចិនរាល់រដូវ កើ្ដ (*) ម៉ែឪចិនអួសអស់ ។

(*) កេរ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ចិនមកពីស្រុកនាយ មានសំពាយជារបស់
មិនទាន់ចេះខ្មែរសោះ គ្មានកេរ្តិ៍(*) កោះស្រែចំការ ។
កវែកចង្ក្រានឆ្នាំង ផ្សំកំលាំងនឹងប្រាជ្ញា
អង្រែកជិះលើស្មា មានម្លូស្លាជាដើមទុន ។
ទំនិញមានគ្រប់មុខ ផ្លាល់ផ្ញើរទុកដាក់ដោយធុន
ចិនវែកមិនដែលពុន ស្រូវជោរជន់ពេញជង្រុក ។
ឈប់វែកដេកអង្គុយ រាប់កាក់លុយប្រមូលទុក
ឪចិនស្រាពីមុខ ទុកជាផ្ទាក់ទាក់កខ្មែរ ។
៨៥- ចិនច្រើនខ្លាំងចិត្តខ្មៅ កន្លាំងតៅធ្វើជាស្រែ
គ្មានត្បាល់គ្មានអង្រែ អង្ករខ្មែរចូលបាវចិន ។
ជាតិខ្មែរច្រើនឥតខ្មាស ស្រែកស្រាណាស់ផឹកជឿសិន
គំនិតគិតមិនឆ្អិន ផឹកបង្ហិនតែទ្រព្យឯង ។
កំណើតអ្នកផឹកស្រា បែកប្រាជ្ញាច្រើនកន្លែង
អ្នកម្យ៉ាងបែកខាងល្បែង មិនគិតក្រែងខ្លាចខ្លួនក្រ ។
អាម្យ៉ាងបែកល្បួចឆក់ មារយាទអាក្រក់មិនបានល្អ
ផឹកចោលការរបរ ចិនទាក់កធ្វើខ្ញុំបាន ។
មិនដឹងខ្លួនជាឆ្កួត និយាយអួតប្រាប់សន្តាន
ថាចិនធ្លាប់រាប់អាន ផឹកថ្មើម៉ានចិនមិនគិត ។
៩០- ថាចិនមិនចេះកាញ់ ប្រាប់សំឡាញ់ពួកម៉ាកមិត្ត
គួកនទោះឆ្ងាយជិត រឹតប្រមូលលុយឱយចិន ។
ត្រូវស្រាចង់ស៊ីឆ្ងាញ់ ធុំផាខ្លាញ់បក់ឆ្លូលក្លិន

(*) កេរ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com


ឃើញបាយសម្លន្លិន ផ្តាប់ចិត្តចិនយកបាយស៊ី ។
ផឹកទឹកបោយត្រឡោក មារយាទទាបថោកឫកសៀវធី
ចិនប្រើសែងរែកលី ស៊ីញយៗចិនមើលងាយ ។
ជាតិចិនកំណាញ់ស្វិត នឹកក្នុងចិត្តមិននិយាយ
មារយាទខ្មែរច្រើនរាយមាយ រលោយទ្រព្យអភ័ព្វខ្លួន ។
ស៊ីឆ្ងាញ់ឆ្អែតស្កប់ស្កល់ ទាបថោកដល់ប្រពន្ធកូន
អាប់យសទាំងបងប្អូន ដល់តាដូនពូជពង្សខ្មែរ ។
៥៩- ជាតិចិនសុទ្ធសឹងស មានទ័លក្រខ្សត់ខ្លះដែរ
ស៊ីផឹកស្និទ្ធតាមសៃ តមបាយខ្មែរមិនស៊ីសោះ ។
មានផ្ទះមានដំណាំ កាប់ដីដាំដោយក្បៀនកោះ
ដំឡូងត្រាវចេកម្នាស់ ស៊ីមិនអស់ទុកលក់ដូរ ។
ខ្មែរច្រើនខ្ជិលប្រមឹក កែងកោងឫកអួតអំបូរ
ខ្វះលុយអង្គុយថ្ងូរ កើបបង្ហូរស្រូវជង្រុក ។
កូនអើយរៀងដំណាំ គួរតែដាំឱ្យគ្រប់មុខ
ដីកេរ្តិ៍(*) ម្តាយឪពុក មិនត្រូវទុកចោលទំនេរ ។
រាជការវាស់មានថ្លៃ ផ្តិតមេដៃផ្តាច់ជាកេរ្តិ៍(*)
មិនវាស់លែងទទេ ររិះយកពន្ធរាល់ឆ្នាំ ។
៦០- ដូងស្វាយអំពៅចេក កុំខ្ជិលពេកដេកប្រចាំ
ម្លូស្លាម្រេចខ្ទឹមថ្នាំ ត្រូវតែដាំកុំឱ្យខ្វះ ។
ទេសឯកសំពត់ស ដីវាលល្អដាំកប្បាស

---
(*) កេរ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



កុំខ្ជិល តាមចាស់ៗ  មនុស្សនឿយណាស់មិនដែលក្រ ។
បន្លែដាំគ្រប់មុខ  យកគ្រាប់ទុកដាំបន្ត
ចាក់ជីជាតិល្អៗ  បង្ការសួពេលល្ងាចព្រឹក ។
ម្លូស្លាថ្នាំខ្ទឹមម្រេច  លូតលាស់លេចពីស្រោចទឹក
បានផលផ្លែឬស្លឹក  កុំឆ្អើងឬកវាក្រខ្លួន ។
ត្រីងៀតផ្អកប្រហុក  ខ្មែរគ្រប់ស្រុកទិញដូរយួន
អំបិលធ្វបក្រមួន  ពីតាដូនតែងដូរទិញ ។
៦៩- ដូរទុកដាក់ដីកល់  ស៊ីឱយដល់ខួបខែវិញ
ឱយបរិបូណ៌ពោរពេញ  ខាតចំណោញកុំទិញតិច ។
អំបិលទិញមួយចុង  ច្រកពេញអុងអាងខាងលិច
កុំទិញក្តោបខ្ចប់វេច  អស់រំពេចគេចទិញទៀត ។
អំបិលមួយស្រូវបី  វាល់នឹងល្អីទូលកណ្តៀត
ខ្លួនក្រត្រូវដរឆ្លៀត  មារយាទយ៉ាងហ្នឹងកុំប្រព្រឹត្ត ។
កូនចៅទាំងប្រុសស្រី  គួរគប្បីប្រុងគំនិត
ចិញ្ចឹមជន្មជីវិត  គិតឱយវែងកុំគិតខ្លី ។
ទំនេរល្ហែធ្វើការ  ស្វត្រូវធមិអាចិទាំងប្រុសស្រី
ឱយត្រឹមត្រូវបាលី  ដូចស្រែដីខាងដើមស្រោប់ ។
៧០- រាល់រូបទាំងប្រុសស្រី  កាលចេះស្តីព្រោះចេះស្តាប់
ម៉ែឪតម្រូវប្រាប់  កូនចៅគ្រាប់តាមដូនតា ។
ចាស់ម្យ៉ាងសាងសីលទាន  មិនបំពានខុសពុទ្ធដីកា
កូនកាត់តាមមេបា  មិនទៅណាឆ្ងាយពីផ្លូវ ។

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ចាស់ម៉្យាងសាងផលកម្ម ស្អប់សីលប្រាំដូចសត្រូវ
កូនកាត់តាមម៉ែឪ អាស្រូវភាសវិនាសខ្លួន ។
មិនជឿមគ្គជឿផល ធ្លាក់ទៅដល់អបាយបួន
កងកម្មចាំគុំគួន គេចវេះពួនមិនកំបាំង ។
ព្រះអង្គមានពុទ្ធដីកា ប្រៀបឧបមាជាទីតាំង
ដូចគោមានកំឡាំង សំរាំងទុកទីមរទេះ ។
៧៩- នឹងបរផ្លូវវៀចត្រង់ ឬនឹងចង់បរគេចវេះ
កងវិលមិនរបេះ ជិះជើងគោមិនឃ្លាតឃ្លា ។
រាល់រូបទាំងតូចធំ ចូលរូងភ្នំ រូងគុហា
យកថ្មផ្ទាំងរាំងទ្វារ កម្មវេរាតោងតាមបាន ។
កងសីលមានអង្គប្រាំ វេរាកម្មជិតដោយដាន
នរកប្រេតតិរច្ឆាន ខានឃាត់ខាំងបាំងមគ្គផល ។
គួរខំសាងសីលទាន យកនិព្វានជាត្រើយថ្កល់
យូរឆាប់គង់តែដល់ កុសលជួយចាកសង្សារ ។
កូនចៅរេរិះគិត មើលគំនិតចិត្តដូនតា
ប្រព្រឹត្តខុសសាសនា គេចកិរិយាកុំធ្វើត្រាប់ ។
៨០- មើលចាស់ណាត្រឹមត្រូវ ចុះក្នុងផ្លូវគន្លងច្បាប់
ចាស់ស្តីគប្បីស្តាប់ ប្រិតប្រៀងប្រាប់ឱយប្រុងចាំ ។
គោរពគុណទាំងបី សូត្របាលីតាមចំណាំ
រក្សាអង្គសីលប្រាំ កម្មវេរាតាមមិនទាន់ ។
សាសនានៅវែងឆ្ងាយ កន្លងឆ្ងាយជាងពីរពាន់

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com


សព្វថ្ងៃលៃខ្មែរគ្មាន់ មិនទាន់គ្រប់ជាប្រាំរយ ។
ឥឡូវចិតប្រាំបី នៅថ្ងៃមួយខាងក្រោយ
ក្មួនចៅកុំបណ្ដោយ ឱយលិចលង់ក្នុងសង្សារ ។
មានពាក្យចាស់ដំណាល ថាកណ្ដាលព្រះសាសនា
ទំនាយក្បួនតម្រា ថានឹងវៀវហើយរឹកវិញ ។
៨៩- ហេតុនេះអស់ក្មួនចៅ ទោះល្ងង់ខ្លៅយ៉ាងណាមិញ
ខំឧស្សាហ៍ទន្ទេញ បំពេញពាក្យពុទ្ធទំនាយ ។
តំណពីថ្ងៃនេះ រៀនត្រិះកុំរាយមាយ
ក្មួនណាមិនស្វាធ្យាយ មិនរលាយរលត់ទុក្ខ ។
ដល់សាសនាគ្រប់គ្រាន់ ជួបប្រាំពាន់ទៅខាងមុខ
ទំនាយរាយទំនុក ថាឪពុកម្ដាយស្អប់ក្មួន ។
ថាកើតអន្តរកប្ប គុំសម្លាប់គ្នាបងប្អូន
មិនដឹងតាដឹងដូន ស្មូន្យសីលទានមិនមានសល់ ។
គួរគិតកុំសាងកម្ម កាន់សីលប្រាំចាំដឹកលល់
ខំសាងមគ្គសាងផល នឹងបានដល់ឋានសាន្តសុខ ។
៩០- នឹងរួចពីកាប់ចាក់ មិនបានធ្លាក់ទៅនរក
ព្រះសិអារ្យគ្រាស់ខាងមុខ រសាយទុក្ខសោករាល់ថ្ងៃ ។
នេះហៅច្បាប់បណ្ដាំ ជាពាក្យប្រាំៗមួយផ្នួន
បទព្រហ្មគ្រប់ឃ្លាប្ចូន ជូនចែងចប់ម្ល៉េះហើយហោង ។

អ្នកព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel